# លោកស្រីចក់ សុភាព៖លោកវន់ ពៅនិងលោកថេង សាវឿនមិនគួររងការផ្តន្ទាទោសទេ



*លោក វន់ ពៅ លោកស្រី ចក់ សុភាព លោកជិន ម៉ាលីន លោក ថេង សាវឿន*

ក្រោយពីបានសង្កេតការណ៍ជុំវិញសវនាការលើសំណុំរឿងលោក វន់ ពៅ និង លោក ថេង សាវឿន ព្រមទាំងជនជាប់ចោទផ្សេងទៀតពាក់ព័ន្ធនឹងការចូលរួមតវ៉ានៅរោងចក្រកាត់ដេរ យ៉ាកជីង កាលពីឆ្នាំ ២០១៤ លោកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បង្ហាញការយល់ឃើញថា យោងតាមអង្គហេតុ និងអង្គច្បាប់ គួបផ្សំនឹងទំនាក់ទំនងដែលលោកស្រីធ្លាប់ប្រាស្រ័យជាមួយ លោក វន់

៣៧ និងលោក ថេង សារឿង លោកស្រីជឿជាក់ថាពួកគេមិនគួរត្រូវបានរងការផ្តន្ទាទោសនោះទេ។ មិនគួររងការផ្តន្ទាទោសដោយពួកគេសុទ្ធតែជាអ្នកអហិង្សានិយម ហើយពួកគេមិនត្រឹមតែជាជនរងគ្រោះពីអំពើហិង្សាដែលកើតឡើងនៅអំឡុងដើមឆ្នាំ២០១៤នោះទេ តែថែមទាំងជាជនរងគ្រោះក្នុងនីតិវិធីដែលពួកគេពុំបានជួបមេធាវីរបស់ពួកគេបន្ទាប់ពីរងហិង្សានោះ រហូតដល់៥ថ្ងៃទើបមេធាវីនិងក្រុមគ្រួសារបានដឹងថាពួកគេត្រូវបានយកទៅឃុំនៅត្រពាំងថ្លុង។ នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសង្ឃឹមថា សាលាឧទ្ធរណ៍នឹងផ្តល់យុត្តិធម៌ដល់ពួកគេ និងអ្នកពាក់ព័ន្ធដទៃទៀត។

ការលើកឡើងរបស់នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជារូបនេះ ត្រូវបានលោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌ឆ្លើយតបតាមរយៈវិទ្យុវាយោនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ថា ការសម្រេចថា លោក វន់ ៣៧ និង លោក ថេង សារឿន ព្រមទាំងជនជាប់ចោទដទៃផ្សេងទៀត មានទោសឬគ្មានទោសមិនអាស្រ័យទៅនឹងអ្វីដែលលោកស្រី ចក់ សុភាព ឬក៏សង្គមស៊ីវិលលើកឡើងនោះទេ ប៉ុន្តែវាអាស្រ័យទៅលើស្ថាប័នដែលមានសមត្ថកិច្ច ពោលគឺតុលាការ។

សំឡេងលោកជិន ម៉ាលីន៖

ចំពោះករណីថាតុលាការអនុវត្តខុសទៅនឹងនីតិវិធីដែលធ្វើឱ្យលោក វន់ ពៅ និង លោក ថេង សាវឿន ពុំអាចសុំជួបមេធាវីរបស់ខ្លួនបាននោះ អ្នកនាំពាក្យក្រសួងយុត្តិធម៌ថា លោកស្រី ចក់ សុភាព អាចប្ដឹងតតាំងនៅក្នុងសវនាការបាន ព្រោះមូលដ្ឋាននៃការប្ដឹងតុលាការអំពីការអនុវត្តខុសនីតិវិធី គឺជាមូលដ្ឋានច្បាប់រឹងមាំណាស់សម្រាប់ប្រឆាំងដើម្បីការពារខ្លួន។ ប៉ុន្តែលោក ជិន ម៉ាលីន សង្កត់ធ្ងន់ថា កន្លងមកភាគីខាងលោក វន់ ពៅ និង លោក ថេង សាវឿន មិនមានមូលដ្ឋានទាំងនេះទេ។

គួររម្លឹកថា សមត្ថកិច្ចបានចាប់ខ្លួនមនុស្សចំនួន១០នាក់ កាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ ដែលបានដឹកនាំកម្មករធ្វើបាតុកម្ម និងមានការប៉ះទង្គិចគ្នារវាងកងសន្តិសុខ និងក្រុមបាតុករដែលជាកម្មករនៅមុខរោងចក្រ យ៉ាក់ ជីង តាមបណ្ដោយផ្លូវជាតិលេខ៤។ មនុស្សទាំង១០នាក់ដែលចាប់ខ្លួនក៏មានលោកវន់ ពៅ និងលោក ថេង សាវឿន ដែរ។ អ្នកទាំងនោះត្រូវបានបញ្ជូនខ្លួនទៅសាលាដំបូងរាជធានីភ្នំពេញកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ និងត្រូវបានចោទប្រកាន់ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងការបំផ្លាញទ្រព្យសម្បត្តិដោយចេតនាមានស្ថានទម្ងន់ទោស។

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង៨ព្រឹក សាលាឧទ្ធរណ៍នឹងប្រកាសសាលក្រមលើសំណុំរឿងលោក វន់ ពៅ ប្រធានសមាគម

ប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងលោក ថេង សារឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) និងបក្ខពួក ពីបទញុះញង់ឱ្យប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម នៅមុខរោងចក្រ យ៉ាក់ ជីង ផ្លូវជាតិលេខ៤ កាលពីដើមឆ្នាំ២០១៩។ ការកំណត់ថ្ងៃប្រកាសសាលក្រមនេះ ធ្វើឡើងបន្ទាប់ពីសាលាឧទ្ធរណ៍បានបើកសវនាការជំនុំជម្រះកាលពីព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣៕